**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ៥២៦ ប្រក.កសក

# ប្រ កា ស

## ស្តីពី

## ការកំណត់គំរូប្រភេទឧបករណ៍នេសាទធក់ត្រី និង ឧបករណ៍នេសាទស្បៃមុងដែលត្រូវហាមឃាត់

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ សេចក្តីប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និង លុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល
- បានឃើញ សេចក្តីប្រកាសលេខ ០២ សប្រក ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការលុបបំបាត់ការប្រើឧបករណ៍នេសាទធក់ត្រី និង ឧបករណ៍នេសាទស្បៃមុង

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh. Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ក្រសួងកសិកម្ម ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- បានឃើញ ប្រកាសលេខ ២៥៩ ប្រក.កសក ចុះថ្ងៃ ទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការហាមឃាត់ប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទ អួនអួសក្រឡាញឹក និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាបនៃព្រះ រាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកដ្ឋានជលផល

## សម្រេច

**ប្រការ១** : កំណត់គំរូប្រភេទឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុងដែលត្រូវហាមឃាត់ដាច់ខាត ដូចមានចែងខាងក្រោមនេះ :

ក- ឧបករណ៍នេសាទឆក់ត្រី

- ឧបករណ៍នេសាទឆក់ត្រីគ្រប់ប្រភេទ
- អាំងវែទ័រ ឬ ឧបករណ៍បំលែងចរន្តអគ្គីសនីពីចរន្តជាប់ទៅចរន្តឆ្លាស់ កម្លាំងលើសពី ២២០ V (ពីររយម្ភៃវ៉ុល)
- ដង និង ខ្សែឆក់ ។

ខ- ឧបករណ៍នេសាទស្បៃមុង

- លូស្បៃមុង ( សៃយ៉ឺនស្បៃមុង ឬ អ៊ុយស្បៃមុង)
- ឡុកស្បៃមុង
- ណស្បៃមុង
- ដាយស្បៃមុង
- ថ្នងស្បៃមុង
- អួនស្បៃមុងទឹកសាប
- របាំងស្បៃមុង
- អញ្ចងស្បៃមុង
- លបស្បៃមុង
- សាប ឬ យ៉ស្បៃមុង
- និង ឧបករណ៍នេសាទស្បៃមុងផ្សេងៗទៀតនៅក្នុងដែននេសាទទឹកសាប ។

**ប្រការ២** : លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង និង ប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៣

រ ដ្ឋ ម ន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ